# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤៧៨ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋផ្ទៃដីទំហំ ២១២៣,៩៩ ហិកតា ស្ថិតនៅភូមិសំរោង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ សម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដី និងខ្វះដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញអនុក្រឹត្យលេខ ១២៩ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់និតិបុគ្គលសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**មាត្រា ១.-**

ត្រូវបានកាត់ចេញពីផែនទីគម្របព្រៃឈើឆ្នាំ ២០០២ ផ្ទៃដីទំហំ ២១២,៣,៩៩ ហិកតា (ពីរពាន់មួយរយម្ភៃបីហិកតា និងកៅសិបប្រាំបួនអា) ស្ថិតនៅភូមិសំរោង ឃុំមានរិទ្ធ ស្រុកសណ្តាន់ ខេត្តកំពង់ធំ ដូចមានបង្ហាញក្នុងផែនទីជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដោយកំណត់តាមចំណុចគោលដែលមាន និយាមកានៃប្រព័ន្ធកូអរដោនេ UTM_ Zone 48 N, WGS 1984 ដូចខាងក្រោម៖

| ចំណុច | X | Y | ចំណុច | X | Y |
|---|---|---|---|---|---|
| 1 | 546213 | 1437074 | 14 | 552270 | 1436324 |
| 2 | 546034 | 1437634 | 15 | 552329 | 1435634 |
| 3 | 546747 | 1439814 | 16 | 552491 | 1435204 |
| 4 | 547143 | 1440124 | 17 | 552604 | 1434574 |
| 5 | 548021 | 1439544 | 18 | 552564 | 1434174 |
| 6 | 548231 | 1439774 | 19 | 551218 | 1433764 |
| 7 | 547604 | 1440324 | 20 | 550791 | 1434524 |
| 8 | 548346 | 1440834 | 21 | 551403 | 1435174 |
| 9 | 549424 | 1440164 | 22 | 551314 | 1435584 |
| 10 | 549863 | 1439534 | 23 | 550291 | 1435044 |
| 11 | 551139 | 1438804 | 24 | 549629 | 1434914 |
| 12 | 551503 | 1437484 | 25 | 549288 | 1434664 |
| 13 | 551947 | 1436674 | 26 | 547867 | 1437414 |

**មាត្រា ២.-**

ត្រូវបានធ្វើអនុបយោគផ្ទៃដីដូចមានចែងក្នុងមាត្រា ១ ខាងលើនៃអនុក្រឹត្យនេះដែលជាដីសាធារណៈរបស់រដ្ឋ មកជាដីឯកជនរបស់រដ្ឋ។

**មាត្រា ៣.-**

ត្រូវបានប្រគល់អាណត្តិកាន់កាប់ដីឯកជនរបស់រដ្ឋដូចមានក្នុងមាត្រា ២ ខាងលើ ជូនអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ជាអាជ្ញាធរកាន់កាប់ដីរដ្ឋ ដើម្បីស្នើសុំចុះបញ្ជីជាដីឯកជនរបស់រដ្ឋសម្រាប់ធ្វើសម្បទានដីសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដសម្រាប់សាងសង់លំនៅដ្ឋាន និងធ្វើកសិកម្មជាលក្ខណៈគ្រួសារ។

**មាត្រា ៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រី គ្រប់ក្រសួង និង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែកញ្ញា. ឆ្នាំ ២០១៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការ រាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការដ្ឋាន គសសជ
-គ្រប់សមាជិក គសសជ
-ដូចមាត្រា ៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ផែនទីបង្ហាញទីតាំងសម្បទានដីសង្គមកិច្ចទំហំ ២១២៣,៩៩ (ពីរពាន់មួយរយម្ភៃបីក្បៀស កៅសិបប្រាំបួន)ហិកតា

ស្ថិតនៅ ឃុំ មានរិទ្ធ ស្រុកសណ្ដាន់ ខេត្តកំពង់ធំ

ឧបសម្ព័ន្ធអនុក្រឹត្យលេខៈ៤៧៨ អនក្រ.បក......ចុះថ្ងៃទី...០១.....ខែកញ្ញា..ឆ្នាំ២០១៣




| ID | X | Y | ID | X | Y |
|---|---|---|---|---|---|
| 1 | 546213 | 1437074 | 14 | 552270 | 1436324 |
| 2 | 546034 | 1437634 | 15 | 552329 | 1435634 |
| 3 | 546747 | 1439814 | 16 | 552491 | 1435204 |
| 4 | 547143 | 1440124 | 17 | 552604 | 1434574 |
| 5 | 548021 | 1439544 | 18 | 552564 | 1434174 |
| 6 | 548231 | 1439774 | 19 | 551218 | 1433764 |
| 7 | 547604 | 1440324 | 20 | 550791 | 1434524 |
| 8 | 548346 | 1440834 | 21 | 551403 | 1435174 |
| 9 | 549424 | 1440164 | 22 | 551314 | 1435584 |
| 10 | 549863 | 1439534 | 23 | 550291 | 1435044 |
| 11 | 551139 | 1438804 | 24 | 549629 | 1434914 |
| 12 | 551503 | 1437484 | 25 | 549288 | 1434664 |
| 13 | 551947 | 1436674 | 26 | 547867 | 1437414 |